ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល
វិជ្ជាជីវៈ និងយុវនីតិសម្បទា
លេខ:...៧០...សកបយ

រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ មករា ឆ្នាំ១៩៩៩

# ប្រកាស

## ស្តីពី

## ការធ្វើការបន្ថែមម៉ោង
## ក្រៅពីម៉ោងធ្វើការធម្មតា

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ស្តីពីការងារដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស-រកម-០៣៩៧-០១ ចុះថ្ងៃទី ១៣ ខែ មិនា ឆ្នាំ ១៩៩៧

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាលេខ នស.រកត ១១៩៨/៧២ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤

## សំរេច

ប្រការ១: ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានដែលស្ថិតក្នុងដែនអនុវត្តនៃច្បាប់ ស្តីពីការងារអាចស្នើសុំការអនុញ្ញាតពីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីធ្វើការបន្ថែមម៉ោងលើសពីថិរវេលាធ្វើការធម្មតារបស់សហគ្រាស គ្រឹះស្ថានរបស់ខ្លួននៅក្នុងករណីដូចតទៅ :-

ក- ដើម្បីឱ្យការងារពិសេសប្រព្រឹត្តទៅបានដូចជា ការធ្វើបញ្ជីសារពើភ័ណ្ឌនិងតុល្យការ ការដាក់កំណត់ពេលវេលាការជំរះបញ្ជី និងការបញ្ឈប់គណនេយ្យ ។

ខ- ដើម្បីឱ្យសហគ្រាសអាចទប់ទល់នឹងការងារដែលមានច្រើនខុសធម្មតាបណ្តាលមកពីកាលៈទេសៈប្លែកៗ ដោយមិនអាចរង់ចាំនិយោជកកើតមានការងារផ្សេងទៀត ។

<u>ប្រការ២</u>: សំណុំលិខិតនៃការស្នើសុំធ្វើការបន្ថែមម៉ោងមានដូចតទៅ :-

១- លិខិតស្នើសុំរបស់សហគ្រាស គ្រឹះស្ថានចំនួន០១ ច្បាប់ ។

២- លិខិតបញ្ជាក់ពីយោបល់ឯកភាពរបស់ប្រតិភូពេញសិទ្ធិគ្រប់រូបរបស់សហគ្រាស គ្រឹះស្ថានឬការឯកភាពពីចំនួនពាក់កណ្តាលនៃកម្មករ និយោជិតបើសហគ្រាស គ្រឹះស្ថានមិនទាន់មានប្រតិភូបុគ្គលិក ចំនួន ០១ ច្បាប់ ។

<u>ប្រការ៣</u>: សហគ្រាស គ្រឹះស្ថានទាំងអស់ដែលមានទីតាំងនៅរាជធានីភ្នំពេញ ត្រូវបញ្ជូនសំណុំលិខិតទៅស្នើសុំធ្វើការបន្ថែមម៉ោងទៅនាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាដែលស្ថិតនៅអគារលេខ២៨ វិថីសម្តេចព្រះធម្មលិខិតអ៊ុក( ផ្លូវលេខ១៨៤) សង្កាត់ជ័យជំនះ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ។ ចំណែកសហគ្រាស គ្រឹះស្ថានមានទីតាំងនៅតាមខេត្ត ក្រុង ដទៃទៀតត្រូវបញ្ជូនសំណុំលិខិតទៅអធិការដ្ឋានសង្គមកិច្ច ខេត្ត-ក្រុង នៃមូលដ្ឋានខ្លួន ។

សំណុំលិខិតនៃការស្នើសុំធ្វើការបន្ថែមម៉ោងត្រូវបញ្ជូនទៅនាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ក្នុងរយៈពេលយ៉ាងតិច១៥ថ្ងៃមុនការចាប់ផ្តើមធ្វើការបន្ថែមម៉ោង ។ ចំពោះខេត្ត ក្រុងដទៃទៀតក្រៅពីរាជធានីភ្នំពេញ ក៏ត្រូវអនុវត្តកាលកំណត់នេះដូចគ្នាដែរ ។

<u>ប្រការ៤</u>: ការរៀបចំធ្វើការបន្ថែមម៉ោងនេះត្រូវផ្អែកលើគោលការណ៍ស្ម័គ្រចិត្តពោលគឺម្ចាស់ឬនាយកសហគ្រាស គ្រឹះស្ថានមិនត្រូវបង្ខិតបង្ខំ ឬដាក់វិន័យផ្សេងៗចំពោះកម្មករ និយោជិតដែលមិនស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោងឡើយ ។

<u>ប្រការ៥</u>: ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានត្រូវផ្តល់ប្រាក់ឈ្នួលធ្វើការបន្ថែមម៉ោងជូនកម្មករ និយោជិតដូចតទៅ :-

ក- ស្មើនឹង១៥០ ភាគរយ ( ឬ១ដងកន្លះ ) នៃប្រាក់ឈ្នួលពេលធ្វើការធម្មតា ចំពោះការធ្វើការបន្ថែមម៉ោងនៅពេលថ្ងៃនៃថ្ងៃធ្វើការធម្មតា ។

ខ- ស្មើនឹង២០០ភាគរយ ( ឬ២ដង ) នៃប្រាក់ឈ្នួលពេលធ្វើការធម្មតាចំពោះការធ្វើការបន្ថែមម៉ោងនៅពេលយប់ ( ពីម៉ោង២២.០០ទៅម៉ោង៥.០០ព្រឹក ) ៕

<u>ប្រការ៦</u>: ចំពោះសហគ្រាសដែលមានកម្មករ និយោជិតធ្វើការពេលយប់ម្ចាស់ ឬ នាយកសហគ្រាស គ្រឹះស្ថានត្រូវផ្តល់ទីកន្លែងសំរាកទទួលទានដំណេកអោយបានសមរម្យដល់កម្មករ និយោជិតដែលចេញពីធ្វើការនៅ ពេលយប់ ពុំនោះសោតទេត្រូវផ្តល់មធ្យោបាយសំរាប់ដឹកជញ្ជូនកម្មករ និយោជិតទៅដល់លំនៅដ្ឋានរៀងៗខ្លួនវិញប្រកបដោយសុវត្ថិភាពនៅពេលចប់ម៉ោងធ្វើការពេលយប់ ។

<u>ប្រការ៧</u>: រាល់ការប្រព្រឹត្តល្មើស នឹងបទប្បញ្ញត្តិនៃប្រកាសនេះត្រូវពិន័យ ឬផ្តន្ទាទោសតាមច្បាប់ដូចមានចែងក្នុងជំពូក

ទី ១៦ នៃច្បាប់ស្តីពីការងារ ។

ប្រការ៨: ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

ចម្លងជូន

- ព្រះរាជលេខាធិការដ្ឋានព្រះមហាក្សត្រ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង "ដើម្បីជ្រាប"
- ក្រសួងពត៌មាន "ដើម្បីផ្សព្វផ្សាយឱ្យបានទូលំទូលាយ"
- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍
- រាជកិច្ច
- គ្រប់អធិការដ្ឋានសង្គមកិច្ច ខេត្ត - ក្រុង
  "ដើម្បីជ្រាប"
- បិទផ្សាយនៅក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា នាយកដ្ឋានអធិការកិច្ចការងារ និងអធិការដ្ឋានសង្គមកិច្ច ខេត្ត-ក្រុង
- កាលប្បវត្តិ និង ឯកសារ